រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៤៤១៥ ប.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូល ពីកម្រៃសេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ស្ដីពីថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្ដោះអាសន្ន និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សម្រាប់ជនបរទេសអន្តោប្រវេសន្ត
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៧៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការកំណត់អាករទិដ្ឋាការ និងអាករទិដ្ឋាការរយៈពេលស្នាក់នៅបណ្ដោះអាសន្ន សម្រាប់ជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៤៩១៤ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ
- យោងតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

ត្រូវបានផ្ដល់ថវិការង្វាន់ជូនក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ ._**

អនុញ្ញាតឱ្យក្រសួងមហាផ្ទៃ បុរេប្រទានថវិការង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានពីការផ្ដល់សេវារដ្ឋបាល ដូចបានកំណត់ដោយប្រកាសអន្តរក្រសួងលេខ ១៤៩១៤ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។

ថវិការង្វាន់ដែលបានបុរេប្រទាននេះ ត្រូវបានអនុញ្ញាតឱ្យក្រសួងមហាផ្ទៃ ប្រើប្រាស់សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។ ថវិការង្វាន់ដែលអនុញ្ញាតឱ្យបុរេប្រទាន រួមមានចំណែកថវិការង្វាន់របស់ក្រសួងមហាផ្ទៃ និងចំណែកថវិការង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣ .–**

ប្រាក់ចំណូលដែលប្រមូលបានពីកម្រៃសេវារដ្ឋបាល ត្រូវបានបែងចែកសម្រាប់បង់ចូលថវិកាជាតិ, ចំណែកថវិការង្វាន់ផ្តល់ជូនក្រសួងមហាផ្ទៃ និងចំណែកថវិការង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្អែកតាមសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ៤ .–**

ការប្រើប្រាស់ថវិការង្វាន់ សម្រាប់ឧបត្ថម្ភលើកទឹកចិត្តមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការនៃក្រសួងមហាផ្ទៃ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៥ .–**

ក្រសួងមហាផ្ទៃត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ថវិការង្វាន់ នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ក្រសួងមហាផ្ទៃត្រូវគ្រោងឥណទានរង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើថវិការង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់ក្រសួងមហាផ្ទៃ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើថវិការង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

**ប្រការ៦ .–**

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ ត្រូវធ្វើសំណើសុំទូទាត់ថវិការង្វាន់សរុបប្រចាំខែ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម ÷

ក. **ផ្នែកចំណូល:** ធ្វើសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល បញ្ជូនមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងគណនាថវិការង្វាន់ និងរបាយការណ៍ចំណាយថវិការង្វាន់ដែលបានអនុវត្តកន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ខ. **ផ្នែកចំណាយ:** ធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ៧ ._**

ការអនុវត្តនីតិវិធីទូទាត់ថវិការង្វាន់ ដែលកំណត់នៅក្នុងប្រការ ៦ ខាងលើនេះ ត្រូវបានលើកលែងការទូទាត់ចំពោះថវិកាចំណូល ២០,៥% ដែលបានអនុញ្ញាតឱ្យដកយកពីប្រាក់ចំណូលលើការផ្តល់ទិដ្ឋាការ និងការផ្តល់ទិដ្ឋាការបន្តការស្នាក់នៅបណ្តោះអាសន្ន ដើម្បីផ្តល់ជូនក្រសួងមហាផ្ទៃ ចំនួន ២០% សម្រាប់ទ្រទ្រង់ការចំណាយចាំបាច់បន្ទាន់ ចៃដន្យ និងជាយថាហេតុជាប្រចាំ សម្រាប់ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសេវាផ្សេងៗទៀត ដែលក្រសួងមហាផ្ទៃរ៉ាប់រងភារកិច្ចជូនរាជរដ្ឋាភិបាល និងផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០,៥% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ៨ ._**

ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម ÷

- ប្រកាសអន្តរក្រសួងលេខ ៣៦៦៧ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសអន្តរក្រសួងលេខ ៨០២៩ ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលកម្រៃសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៦៦៧ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គស្នងការ អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៦

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** |
| **ក្រសួងមហាផ្ទៃ** | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |
| **សម្តេចក្រឡាហោម ស ខេង** | **បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន** |

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ......១៤៤១៥.ប្រក ចុះថ្ងៃទី.....៣០... ខែ......ធ្នូ...... ឆ្នាំ២០១៦

ស្តីពីការផ្តល់ថវិការទូទាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

| ល.រ | ប្រភេទសេវា | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក មផ | ក សហវ |
| **I. អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** | | | | |
| ក- កិច្ចការសញ្ជាតិ | | | | |
| 1 | ការស្នើសុំចូលសញ្ជាតិខ្មែរ | 40% | 59% | 1% |
| 2 | ការស្នើសុំលះបង់សញ្ជាតិខ្មែរ | 40% | 59% | 1% |
| 3 | ការស្នើសុំទាមទារសញ្ជាតិខ្មែរ | 40% | 59% | 1% |
| ខ- កិច្ចការអត្រានុកូលដ្ឋាន | | | | |
| 4 | ការស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយប្រជាពលរដ្ឋខ្មែរ | 0% | 0% | 0% |
| គ- កិច្ចការស្ថិតិប្រជាពលរដ្ឋ | | | | |
| 5 | ការផ្តល់សៀវភៅស្នាក់នៅ | 0% | 0% | 0% |
| 6 | ទុតិយតា ឬ តតិយតាសៀវភៅស្នាក់នៅ | 0% | 0% | 0% |
| 7 | ការស្នើសុំបន្ថែម ឬ បន្ថយសមាជិកគ្រួសារក្នុងសៀវភៅស្នាក់នៅ | 0% | 0% | 0% |
| 8 | ការផ្តល់សៀវភៅគ្រួសារ | 0% | 0% | 0% |
| 9 | ទុតិយតា ឬ តតិយតាសៀវភៅគ្រួសារ | 0% | 0% | 0% |
| 10 | ការស្នើសុំបន្ថែម ឬ បន្ថយសមាជិកគ្រួសារក្នុងសៀវភៅគ្រួសារ | 0% | 0% | 0% |

| ល.រ | ប្រភេទសេវា | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក មផ | ក សហវ |
| ឃ-កិច្ចការអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | | | | |
| 11 | ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 0% | 0% | 0% |
| 12 | ទុតិយតា ឬ តតិយតាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 0% | 0% | 0% |
| ង-កិច្ចការលិខិតឆ្លងដែន | | | | |
| 13 | ការបន្តសុពលភាពលិខិតឆ្លងដែន | 10% | 89% | 1% |
| 14 | ការផ្តល់លិខិតឆ្លងដែនគំរូថ្មី (សម្រាប់មនុស្សចាស់ ៦៤ទំព័រ) | | | |
| | - សេវាធម្មតា | 89.5% | 10% | 0.5% |
| | - សេវាឆាប់រហ័សកម្រិតមធ្យម | 89.5% | 10% | 0.5% |
| | - សេវាឆាប់រហ័ស | 89.5% | 10% | 0.5% |
| 15 | ការផ្តល់លិខិតឆ្លងដែនគំរូថ្មី (សម្រាប់កូនក្មេង ៤៨ទំព័រ) | | | |
| | - សេវាធម្មតា | 89.5% | 10% | 0.5% |
| | - សេវាឆាប់រហ័សកម្រិតមធ្យម | 89.5% | 10% | 0.5% |
| | - សេវាឆាប់រហ័ស | 89.5% | 10% | 0.5% |
| II. **អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន** | | | | |
| 16 | ការតម្កល់ទុកឯកសារស្នើសុំបង្កើតអង្គការ សមាគម ឬ សហគមន៍ | 40% | 59% | 1% |
| 17 | ការបើកសាខា ការកែសម្រួលរចនាសម្ព័ន្ធ និងលក្ខន្តិកៈរបស់អង្គការ សមាគម ឬ សហគមន៍ | 40% | 59% | 1% |

| ល.រ | ប្រភេទសេវា | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក មជ | ក សហវ |
| **III. អគ្គស្នងការនគរបាលជាតិ** | | | | |
| 18 | ការផ្តល់ប័ណ្ណប្រើប្រាស់រំសេវ គ្រឿងផ្ទុះ | 10% | 89% | 1% |
| 19 | ការផ្តល់ប័ណ្ណប្រើប្រាស់អាវុធលក្ខណៈបុគ្គល | 10% | 89% | 1% |
| 20 | សេវាការពារដឹកជញ្ជូនរំសេវ គ្រឿងផ្ទុះ (1 នាក់) | 10% | 89% | 1% |
| 21 | ការផលិតត្រាទឹក | 10% | 89% | 1% |
| 22 | ការផលិតត្រាស្ងួត | 10% | 89% | 1% |
| 23 | ការស្នើសុំលិខិតអនុញ្ញាតបើកក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 30% | 69% | 1% |
| 24 | ការស្នើសុំលិខិតអនុញ្ញាតជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាស ឬ គ្រឹះស្ថាននានា | 30% | 69% | 1% |
| 25 | ការស្នើសុំលិខិតបញ្ជាក់ និងបន្តកិច្ចសន្យាជាថ្មីរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 30% | 69% | 1% |
| 26 | ការស្នើសុំលិខិតបញ្ជាក់ និងបន្តកិច្ចសន្យាជាថ្មីរបស់សហគ្រាស ឬ គ្រឹះស្ថាននានា | 30% | 69% | 1% |
| 27 | ការស្នើសុំផ្លាស់ប្តូរអគ្គនាយក ឬ ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 30% | 69% | 1% |
| 28 | ការស្នើសុំផ្លាស់ប្តូរស្លាកសញ្ញា (Logo) នៃក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 30% | 69% | 1% |
| 29 | ការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់រថយន្តដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃរបស់សន្តិសុខគ្រប់ប្រភេទ | 30% | 69% | 1% |

| ល.រ | ប្រភេទសេវា | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក មផ | ក សហវ |
| 30 | កម្រៃសេវានៃកិច្ចសហការរវាងក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលអនុលោមតាមកិច្ចសន្យារវាងភាគីទាំងពីរ | | | |
| | - ចំនួនបុគ្គលិកតិចជាង 100 នាក់ | 30% | 69% | 1% |
| | - ចំនួនបុគ្គលិកចាប់ពី 100 នាក់ ដល់ 299 នាក់ | 30% | 69% | 1% |
| | - ចំនួនបុគ្គលិកចាប់ពី 300 នាក់ ដល់ 499 នាក់ | 30% | 69% | 1% |
| | - ចំនួនបុគ្គលិកចាប់ពី 500 នាក់ ដល់ 999 នាក់ | 30% | 69% | 1% |
| | - ចំនួនបុគ្គលិកចាប់ពី 1 000 នាក់ ឡើងទៅ | 30% | 69% | 1% |
| 31 | កម្រៃសេវានៃកិច្ចសហការរវាងសហគ្រាស ឬ គ្រឹះស្ថាននានា ជាមួយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលអនុលោមតាមកិច្ចសន្យារវាងភាគីទាំងពីរ | | | |
| | - ចំនួនបុគ្គលិកចាប់ពី 1 នាក់ ដល់ 49 នាក់ | 30% | 69% | 1% |
| | - ចំនួនបុគ្គលិកចាប់ពី 50 នាក់ ឡើងទៅ | 30% | 69% | 1% |
| 32 | ការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះ ÷ | | | |
| | - ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលផ្តល់សេវាសន្តិសុខ ដោយគ្មានការអនុញ្ញាតពីក្រសួងមហាផ្ទៃ | 50% | 49% | 1% |
| | - សហគ្រាស ឬ គ្រឹះស្ថាននានាដែលជ្រើសរើសសន្តិសុខឯកជន ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត | 50% | 49% | 1% |

| ល.រ | ប្រភេទសេវា | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ក មផ | ក សហវ |
| IV. **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | | | | |
| 33 | ការផ្តល់ប័ណ្ណឆ្លងដែន | 79% | 20% | 1% |
| 34 | ផ្តល់លិខិតបើកផ្លូវ ជូនជនបរទេសអន្តោប្រវេសន្ត | 35% | 64% | 1% |
| 35 | ពន្យារពេលលិខិតបើកផ្លូវ ជូនជនបរទេសអន្តោប្រវេសន្ត | 35% | 64% | 1% |
| 36 | ផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនជនបរទេសអន្តោប្រវេសន្ត | 35% | 64% | 1% |
| 37 | ទុតិយតាប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនជនបរទេសអន្តោប្រវេសន្ត | 35% | 64% | 1% |
| 38 | ពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនជនបរទេសអន្តោប្រវេសន្ត | 35% | 64% | 1% |
| 39 | ការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះ ÷ | | | |
| | - ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ | 50% | 49% | 1% |
| | - ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលធ្វើសកម្មភាពផ្ទាល់ខ្លួនខុសពីប្រភេទ ទិដ្ឋាការដែលបានផ្តល់ជូន | 50% | 49% | 1% |
| | - ពលករបរទេស ដែលគ្មានប័ណ្ណការងារចេញដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | 50% | 49% | 1% |